# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

**គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត**
**លេខ:** ០៥៧ គ.ជ.ប.ស.ជ.ណ

# សេចក្តីជូនដំណឹង
## ស្តីពី
## ការជ្រើសរើសសមាសភាពគណៈកម្មការរាជធានី ខេត្តរៀបចំការបោះឆ្នោត

គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត (គ.ជ.ប) សូមជម្រាបជូនសាធារណជនឱ្យបានជ្រាបថា គ.ជ.ប ត្រូវការជ្រើសរើសសមាសភាពគណៈកម្មការរាជធានី ខេត្តរៀបចំការបោះឆ្នោត (គធ.ខប) ចំនួន **១៧៥ រូប** ជាមន្ត្រីជាប់កិច្ចសន្យារយៈពេលខ្លី ឱ្យបម្រើការងារនៅគណៈកម្មការរាជធានី ខេត្តរៀបចំការបោះឆ្នោត សម្រាប់ការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ នីតិកាលទី៧ ឆ្នាំ២០២៣។ សមាសភាព គធ.ខប សម្រាប់រាជធានី ខេត្តនីមួយៗ មានចំនួន **០៧ រូប** ដែលមានមុខតំណែងដូចខាងក្រោម ៖

| | |
|---|---|
| ១- ប្រធានគណៈកម្មការរាជធានី ខេត្តរៀបចំការបោះឆ្នោត | ចំនួន ០១ រូប |
| ២- អនុប្រធានគណៈកម្មការរាជធានី ខេត្តរៀបចំការបោះឆ្នោត | ចំនួន ០១ រូប |
| ៣- សមាជិកទទួលបន្ទុកផ្នែករដ្ឋបាល | ចំនួន ០១ រូប |
| ៤- សមាជិកទទួលបន្ទុកផ្នែកហិរញ្ញវត្ថុ | ចំនួន ០១ រូប |
| ៥- សមាជិកទទួលបន្ទុកផ្នែកប្រតិបត្តិការបោះឆ្នោត និងបច្ចេកទេស | ចំនួន ០១ រូប |
| ៦- សមាជិកទទួលបន្ទុកផ្នែកសេវាកម្មច្បាប់ វិវាទកម្ម និងសន្តិសុខបោះឆ្នោត | ចំនួន ០១ រូប |
| ៧- សមាជិកទទួលបន្ទុកផ្នែកអប់រំ ព័ត៌មាន និងទំនាក់ទំនងសាធារណៈ | ចំនួន ០១ រូប |

សាធារណជនដែលមានបំណងដាក់ពាក្យជាបេក្ខជនតាមមុខតំណែងខាងលើនេះ សូមអញ្ជើញមកទំនាក់ទំនងទទួល និងដាក់ពាក្យសុំប្រឡងចូលបម្រើការងារនៅរៀងរាល់ម៉ោងធ្វើការ នៅលេខាធិការដ្ឋានរាជធានី ខេត្តរៀបចំការបោះឆ្នោត ដែល គ.ជ.ប បានកំណត់សម្រាប់ធ្វើជាកន្លែងចែកពាក្យ និងទទួលពាក្យ ។

ពាក្យសុំប្រឡងចូលបម្រើការងារនឹងមានចែកជូនដោយឥតគិតថ្លៃ។ បេក្ខជនអាចទាញយកពាក្យសុំប្រឡងចូលបម្រើការងារតាមរយៈគេហទំព័ររបស់ គ.ជ.ប អាសយដ្ឋាន (www.nec.gov.kh ) ឬស្កេន QR-Code ដូចមាននៅក្នុងសេចក្តីជូនដំណឹងនេះ។

សញ្ញាបត្រ ឬ/និងលិខិតបញ្ជាក់ពីបទពិសោធន៍ការងារត្រូវធ្វើនីត្យានុកូលកម្ម ឬមានការបញ្ជាក់ពីសាមីស្ថាប័ន។

- ការចាប់ផ្តើមចែកពាក្យ និងទទួលពាក្យ ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២២ ( វេលាម៉ោង ៧:០០ នាទីព្រឹក )
- ការឈប់ទទួលពាក្យ ថ្ងៃទី៦ ខែមករា ឆ្នាំ២០២៣ ( វេលាម៉ោង ១៧:៣០ នាទីល្ងាច )។

ថ្ងៃអង្គារ ៥ កើត ខែបុស្ស ឆ្នាំខាល ចត្វាស័ក ព.ស.២៥៦៦
រាជធានីភ្នំពេញ ថ្ងៃទី ២៧ ខែ ធ្នូ ឆ្នាំ២០២២
**ជ.គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត**
**ប្រធាន**

ប្រាជ្ញ ចន្ទ

ស្កេន QR-Code

ដើម្បីទាញយកពាក្យសុំចូលបម្រើការងារ

# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត

លេខ: ០៤៤ គ.ជ.ប.សជ.ន.៣៧

# សេចក្តីជូនដំណឹង
## ស្តីពី
## លក្ខខណ្ឌនៃការជ្រើសរើសសមាសភាពគណៈកម្មការរាជធានី ខេត្តរៀបចំការបោះឆ្នោត

គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត (គ.ជ.ប) សូមជម្រាបជូនសាធារណជនឱ្យបានជ្រាបថា គ.ជ.ប ត្រូវការជ្រើសរើសសមាសភាពគណៈកម្មការរាជធានី ខេត្តរៀបចំការបោះឆ្នោត (គជ.ខប) ចំនួន **១៧៥ រូប** ជាមន្ត្រីជាប់កិច្ចសន្យារយៈពេលខ្លី ឱ្យបម្រើការងារនៅគណៈកម្មការរាជធានី ខេត្តរៀបចំការបោះឆ្នោត សម្រាប់ការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ នីតិកាលទី៧ ឆ្នាំ២០២៣។ សមាសភាព គជ.ខប សម្រាប់រាជធានី ខេត្តនីមួយៗមានចំនួន **០៧ រូប** ដែលមានមុខតំណែងដូចខាងក្រោម ៖

| | |
|---|---|
| ១- ប្រធានគណៈកម្មការរាជធានី ខេត្តរៀបចំការបោះឆ្នោត | ចំនួន ០១ រូប |
| ២- អនុប្រធានគណៈកម្មការរាជធានី ខេត្តរៀបចំការបោះឆ្នោត | ចំនួន ០១ រូប |
| ៣- សមាជិកទទួលបន្ទុកផ្នែករដ្ឋបាល | ចំនួន ០១ រូប |
| ៤- សមាជិកទទួលបន្ទុកផ្នែកហិរញ្ញវត្ថុ | ចំនួន ០១ រូប |
| ៥- សមាជិកទទួលបន្ទុកផ្នែកប្រតិបត្តិការបោះឆ្នោត និងបច្ចេកទេស | ចំនួន ០១ រូប |
| ៦- សមាជិកទទួលបន្ទុកផ្នែកសេវាកម្មច្បាប់ វិវាទកម្ម និងសន្តិសុខបោះឆ្នោត | ចំនួន ០១ រូប |
| ៧- សមាជិកទទួលបន្ទុកផ្នែកអប់រំ ព័ត៌មាន និងទំនាក់ទំនងសាធារណៈ | ចំនួន ០១ រូប |

### I- លក្ខខណ្ឌទូទៅនៃបេក្ខជន ៖

- មានសញ្ជាតិខ្មែរពីកំណើត
- មានអាយុចាប់ពី ២៥ឆ្នាំឡើងទៅ គិតដល់ថ្ងៃតែងតាំង
- មានសិទ្ធិបោះឆ្នោត នៅក្នុងរាជធានី ខេត្ត
- មានសញ្ញាបត្រ ឬបទពិសោធន៍ក្នុងការរៀបចំចាត់ចែងការងារបោះឆ្នោត
- មានបទពិសោធន៍ការងារតាមមុខតំណែង
- មានសុខភាពល្អ
- មានចរិតស្មោះត្រង់ និងសុចរិតទៀងត្រង់ គោរពច្បាប់
- មិនត្រូវជាសហព័ទ្ធ ឬញាតិលោហិត ឬញាតិពន្ធរហូតដល់ថ្នាក់ទី៣ នៅក្នុងគណៈកម្មការតែមួយ

- មិនមែនជាសមាជិកកងយោធពលខេមរភូមិន្ទ ឬនគរបាលជាតិ
- មិនមែនជាមន្ត្រីតុលាការ
- មិនមែនជាព្រះសង្ឃ ឬបព្វជិតសាសនា
- មិនមែនជាអភិបាល អភិបាលរងរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ សមាជិកក្រុមប្រឹក្សារាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់
- មិនមែនជាមេភូមិ ឬជំនួយការមេភូមិ
- មិនមែនជាជនដែលតុលាការផ្តន្ទាទោស ដាក់ពន្ធនាគារពីបទឧក្រិដ្ឋ ឬបទមជ្ឈិម ហើយដែលមិនទាន់មាននីតិសម្បទាឡើងវិញ
- ប្រធាន អនុប្រធាន និងសមាជិក គជ.ខប ដែលជាសមាជិកគណបក្សនយោបាយ ឬ/និងអ្នកដឹកនាំនៃអង្គការមិនមែនរដ្ឋាភិបាល សមាគម សហជីព ឬ/និងមន្ត្រីរាជការ ក្រោយពីបានទទួលការតែងតាំងត្រូវលាលែងពីសមាជិកនៃគណបក្សនយោបាយ ឬ/និងអ្នកដឹកនាំនៃអង្គការមិនមែនរដ្ឋាភិបាល សមាគម សហជីព ឬ/និងត្រូវដាក់ពាក្យសុំទៅបម្រើការងារក្រៅក្របខ័ណ្ឌដើម រហូតដល់ថ្ងៃចប់ភារកិច្ច
- បេក្ខនារី ឬ បេក្ខជន និងបេក្ខនារីដែលជាជនជាតិដើមភាគតិចនៅតំបន់ដែលមានជនជាតិដើមភាគតិចតាមចំនួនសមស្រប និងចំពោះបេក្ខជន និងបេក្ខនារីជាជនមានពិការភាពដែលមានសមត្ថភាព និងកាយសម្បទាសមស្របទៅនឹងមុខតំណែងត្រូវបានលើកទឹកចិត្ត។

## II- លក្ខខណ្ឌបច្ចេកទេសដែលទាមទារដើម្បីបំពេញការងារជាក់លាក់មួយចំនួនដូចជា ៖

- មានចំណេះដឹងទាក់ទងជាមួយមុខតំណែង
- សម្រាប់តួនាទីមួយចំនួនទាមទារឱ្យមានការយល់ដឹង និងចេះប្រើប្រាស់កុំព្យូទ័រ
- មានលទ្ធភាពធ្វើដំណើរក្នុងព្រះរាជាណាចក្រកម្ពុជា។

## III- លក្ខខណ្ឌដោយឡែក សម្រាប់មុខតំណែងដូចខាងក្រោម ៖

- ប្រធាន-អនុប្រធានគណៈកម្មការរាជធានី ខេត្តរៀបចំការបោះឆ្នោត បេក្ខជនត្រូវមានសញ្ញាបត្រចាប់ពីបរិញ្ញាបត្រ ឬបទពិសោធន៍ក្នុងការគ្រប់គ្រង និងចាត់ចែងការងារបោះឆ្នោតយ៉ាងតិច ៥ដង ឬការងារត្រូវនឹងការងារគ្រប់គ្រងយ៉ាងតិច ៥ឆ្នាំ
- សមាជិកទទួលបន្ទុកផ្នែករដ្ឋបាល បេក្ខជនត្រូវមានសញ្ញាបត្រ ចាប់ពីបរិញ្ញាបត្ររង ឬបទពិសោធន៍ក្នុងការងារគ្រប់គ្រង និងចាត់ចែងការងាររដ្ឋបាលបោះឆ្នោតយ៉ាងតិច ៣ដង ឬបទពិសោធន៍ការងាររដ្ឋបាលយ៉ាងតិច ៣ឆ្នាំ
- សមាជិកទទួលបន្ទុកផ្នែកហិរញ្ញវត្ថុ បេក្ខជនត្រូវមានសញ្ញាបត្រ ចាប់ពីបរិញ្ញាបត្ររង ឬបទពិសោធន៍ក្នុងការងារគ្រប់គ្រង និងចាត់ចែងការងារហិរញ្ញវត្ថុបោះឆ្នោតយ៉ាងតិច ៣ដង ឬបទពិសោធន៍ខាងការងារហិរញ្ញវត្ថុ យ៉ាងតិច ៣ឆ្នាំ
- សមាជិកទទួលបន្ទុកផ្នែកប្រតិបត្តិការបោះឆ្នោត និងបច្ចេកទេស បេក្ខជនត្រូវមានសញ្ញាបត្រ ចាប់ពីបរិញ្ញាបត្ររង ឬបទពិសោធន៍ការងារគ្រប់គ្រង និងចាត់ចែងការងារប្រតិបត្តិការបោះឆ្នោតយ៉ាងតិច ៣ដង ឬបទពិសោធន៍ការងារក្នុងការចាត់ចែងប្រតិបត្តិការធំទូលាយយ៉ាងតិច ៣ឆ្នាំ

- សមាជិកទទួលបន្ទុកផ្នែកសេវាកម្មច្បាប់ វិវាទកម្ម និងសន្តិសុខបោះឆ្នោត បេក្ខជនត្រូវមានសញ្ញាបត្រ ចាប់ពីបរិញ្ញាបត្ររង ឬបទពិសោធន៍ក្នុងការងារគ្រប់គ្រង និងចាត់ចែងការងារច្បាប់បោះឆ្នោតយ៉ាងតិច ៣ដង ឬបទពិសោធន៍ខាងការងារច្បាប់យ៉ាងតិច ៣ឆ្នាំ
- សមាជិកទទួលបន្ទុកផ្នែកអប់រំ ព័ត៌មាន និងទំនាក់ទំនងសាធារណៈ បេក្ខជនត្រូវមានសញ្ញាបត្រ ចាប់ពីបរិញ្ញាបត្ររង ឬបទពិសោធន៍ក្នុងការងារគ្រប់គ្រង និងចាត់ចែងការងារអប់រំបោះឆ្នោតយ៉ាងតិច ៣ដង ឬបទពិសោធន៍ការងារបណ្តុះបណ្តាលអប់រំ ព័ត៌មាន និងទំនាក់ទំនងសាធារណៈយ៉ាងតិច ៣ឆ្នាំ។

## IV- **ភារកិច្ច និងការទទួលខុសត្រូវ នៃ គជ.ខប**

គណៈកម្មការរាជធានី ខេត្តរៀបចំការបោះឆ្នោតមានតួនាទី ភារកិច្ច ៖

១- អនុវត្តភារកិច្ចដែលច្បាប់ បទបញ្ជា និងនីតិវិធីនៃការបោះឆ្នោត និងលិខិតបទដ្ឋាននានាដែលបានអនុញ្ញាត ឬតម្រូវឱ្យអនុវត្ត។

២- អនុវត្តភារកិច្ច និងសិទ្ធិដទៃទៀតដែលគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតប្រគល់ឱ្យ។

ភារកិច្ច និងការទទួលខុសត្រូវសំខាន់ៗរបស់ គជ.ខប មានដូចខាងក្រោម ៖

- គោរព និងអនុវត្តបទបញ្ជា និងនីតិវិធី និងគោលការណ៍ណែនាំរបស់ គ.ជ.ប
- អនុវត្តផែនការមេ និងប្រតិទិននៃការបោះឆ្នោត
- គ្រប់គ្រងថវិការបស់ គជ.ខប អនុលោមតាមបទបញ្ជា និងនីតិវិធី និងសេចក្តីណែនាំនានារបស់ គ.ជ.ប
- ចាត់គ្រប់វិធានការចាំបាច់ ដើម្បីធានាឱ្យការបោះឆ្នោតប្រព្រឹត្តទៅដោយសេរី ត្រឹមត្រូវ និងយុត្តិធម៌តាមរយៈការបោះឆ្នោតដោយសម្ងាត់
- ជ្រើសរើសបុគ្គលិកសម្រាប់ លគជ.ខប យោងតាមសេចក្តីណែនាំរបស់ គ.ជ.ប
- ការពារ និងធានាឱ្យបាននូវឯករាជភាព និងអព្យាក្រឹតភាពរបស់ គជ.ខប
- ជ្រើសរើស និងគ្រប់គ្រងសមាសភាព គឃ.សប
- ត្រួតពិនិត្យដំណើរការរៀបចំការបោះឆ្នោតក្នុងរាជធានី ខេត្ត
- បូកសរុប ត្រួតពិនិត្យលទ្ធផលនៃការបោះឆ្នោតក្នុងរាជធានី ខេត្ត និងប្រគល់កំណត់ហេតុទៅ គ.ជ.ប
- បណ្តុះបណ្តាលបុគ្គលិក សមាជិកគណៈកម្មការរាជធានី ខេត្ត ឃុំ សង្កាត់រៀបចំការបោះឆ្នោត និងការិយាល័យបោះឆ្នោត និងរាប់សន្លឹកឆ្នោត
- សហការជាមួយគណបក្សនយោបាយ សមាគម និងអង្គការមិនមែនរដ្ឋាភិបាលនៅក្នុងរាជធានី ខេត្ត លើការងារអប់រំអ្នកបោះឆ្នោត និងការងារពាក់ព័ន្ធផ្សេងទៀត ដើម្បីឱ្យដំណើរការរៀបចំការបោះឆ្នោតប្រព្រឹត្តទៅដោយសេរី ត្រឹមត្រូវ និងយុត្តិធម៌
- សហការជាមួយអាជ្ញាធរគ្រប់ថ្នាក់ក្នុងរាជធានី ខេត្តដើម្បីឱ្យដំណើរការរៀបចំការបោះឆ្នោតប្រព្រឹត្តទៅប្រកបដោយសន្តិសុខ សុវត្ថិភាព និងដោយលក្ខណៈសេរី ត្រឹមត្រូវ និងយុត្តិធម៌
- អនុវត្តការដាក់ ការទទួល និងការដោះស្រាយបណ្តឹង និងវិវាទកម្មក្នុងសមត្ថកិច្ចរបស់ខ្លួន
- ក្តាប់សភាពការណ៍ព័ត៌មានជុំវិញការរៀបចំការបោះឆ្នោត ដើម្បីធ្វើការបំភ្លឺមកស្រាយ ឬដោះស្រាយ និងរាយការណ៍ទៅ គ.ជ.ប ឱ្យបានទាន់ពេលវេលា។

V- **រយៈពេលបម្រើការងារ**

ចាប់ផ្ដើមចូលបម្រើការងារពីថ្ងៃទី១៦ ខែមីនា ឆ្នាំ២០២៣ ដល់ថ្ងៃទី៣១ ខែសីហា ឆ្នាំ២០២៣។

VI- **ប្រាក់កម្រៃ**

- ប្រធាន គធ.ខប ប្រាក់កម្រៃក្នុងមួយខែទទួលបាន ៦.៤១៦.000 រៀល
- អនុប្រធាន គធ.ខប ប្រាក់កម្រៃក្នុងមួយខែទទួលបាន ៥.១៧៦.000 រៀល
- សមាជិក គធ.ខប ប្រាក់កម្រៃក្នុងមួយខែទទួលបាន ៣.៨៤០.000 រៀល។

VII- **ទំនាក់ទំនងព័ត៌មាន**

សាធារណជនដែលមានបំណងដាក់ពាក្យជាបេក្ខជនតាមមុខតំណែងខាងលើនេះ សូមអញ្ជើញមកទំនាក់ទំនងទទួល និងដាក់ពាក្យសុំប្រឡងចូលបម្រើការងារនៅរៀងរាល់ម៉ោងធ្វើការ នៅតាមលេខាធិការដ្ឋានរាជធានី ខេត្តរៀបចំការបោះឆ្នោត ដែល គ.ជ.ប បានកំណត់សម្រាប់ធ្វើជាកន្លែងចែកពាក្យ និងទទួលពាក្យ ។

ពាក្យសុំប្រឡងចូលបម្រើការងារនឹងមានចែកជូនដោយឥតគិតថ្លៃ។ បេក្ខជនអាចទាញយកពាក្យសុំប្រឡងចូលបម្រើការងារតាមរយៈគេហទំព័ររបស់ គ.ជ.ប (www.nec.gov.kh) ឬស្កេន QR-Code លើសេចក្ដីជូនដំណឹងផ្សព្វផ្សាយ។

VIII - **វិញ្ញាសាប្រឡង**

- សំណួរសរសេរ-QCM ទាក់ទងនឹងមុខតំណែង
- សម្ភាសន៍ចំណេះដឹងទូទៅទាក់ទងនឹងការងារបោះឆ្នោត។

IX - **កាលបរិច្ឆេទនៃការទទួលពាក្យ និងការប្រឡងសរសេរ-QCM និងសម្ភាសន៍**

- ការចាប់ផ្ដើមទទួលពាក្យ ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២២ (វេលាម៉ោង ៧:០០ នាទីព្រឹក)
- ការឈប់ទទួលពាក្យ ថ្ងៃទី៦ ខែមករា ឆ្នាំ២០២៣ (វេលាម៉ោង ១៧:៣០ នាទីល្ងាច)
- **រាជធានី និងខេត្តក្រុមទី១** ត្រូវធ្វើការពិនិត្យពាក្យ និងសម្រាំងបេក្ខជន និងបិទផ្សាយបញ្ជីឈ្មោះប្រឡង នៅថ្ងៃទី៧-៨ ខែមករា ឆ្នាំ២០២៣ នឹងប្រឡងនៅថ្ងៃទី១៣ ខែមករា ឆ្នាំ២០២៣ រួមមាន **ខេត្តកំពង់ឆ្នាំង ខេត្តបាត់ដំបង ខេត្តកំពង់ធំ ខេត្តកំពង់ស្ពឺ ខេត្តតាកែវ ខេត្តព្រៃវែង ខេត្តមណ្ឌលគិរី ខេត្តក្រចេះ ខេត្តបន្ទាយមានជ័យ ខេត្តកំពង់ចាម ខេត្តកែប និងរាជធានីភ្នំពេញ។**
- **ខេត្តក្រុមទី២** ត្រូវធ្វើការពិនិត្យពាក្យ និងសម្រាំងបេក្ខជន និងបិទផ្សាយបញ្ជីឈ្មោះប្រឡង នៅថ្ងៃទី៩-១០ ខែមករា ឆ្នាំ២០២៣ នឹងប្រឡងនៅថ្ងៃទី១១ ខែមករា ឆ្នាំ២០២៣ រួមមាន **ខេត្តពោធិ៍សាត់ ខេត្តប៉ៃលិន ខេត្តសៀមរាប ខេត្តកោះកុង ខេត្តកំពត ខេត្តស្វាយរៀង ខេត្តរតនគិរី ខេត្តស្ទឹងត្រែង ខេត្តឧត្ដរមានជ័យ ខេត្តព្រះវិហារ ខេត្តត្បូងឃ្មុំ ខេត្តព្រះសីហនុ និងខេត្តកណ្ដាល។**

X- **ការអនុវត្តតាមបទបញ្ជាផ្ទៃក្នុងនៃគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត**

អនុគណៈកម្មការរៀបចំការប្រឡងតាមរាជធានី ខេត្ត ត្រូវពិនិត្យសំណុំលិខិតរបស់បេក្ខជនដោយត្រូវធ្វើការពិនិត្យ និងជ្រើសរើសយកបេក្ខជនណាដែលមានលក្ខខណ្ឌល្អជាងគេ មកប្រឡងសរសេរ-QCM និងសម្ភាសន៍។

សំណុំលិខិតរបស់បេក្ខជនមិនត្រូវបានប្រគល់ជូនវិញទេ។

XI- **លទ្ធផលនៃការប្រឡងសរសេរ-QCM និងសម្ភាសន៍**

លទ្ធផលនៃការប្រឡងសរសេរ-QCM និងសម្ភាសន៍ នឹងបិទផ្សាយនៅតាមលេខាធិការដ្ឋានរាជធានី ខេត្ត រៀបចំការបោះឆ្នោត និងផ្សព្វផ្សាយនៅលើគេហទំព័ររបស់ គ.ជ.ប ។

**<u>បញ្ជាក់បន្ថែម</u>** ÷

- សញ្ញាបត្រ ឬ/និងលិខិតបញ្ជាក់ពីបទពិសោធន៍ការងារត្រូវធ្វើនីត្យានុកូលកម្ម ឬមានការបញ្ជាក់ពីសាមីស្ថាប័ន
- គ្រប់បេក្ខជនត្រូវមានអ្នកធានាដឹងឮយ៉ាងតិចមួយនាក់
- បេក្ខជនទាំងអស់ត្រូវធានាថា ក្រោយពីពេលដែលត្រូវបានជ្រើសរើសឱ្យចូលបម្រើការងារក្នុងមុខតំណែងណាមួយនោះ ត្រូវសុខចិត្តទទួលយកប្រាក់កម្រៃដូចបានកំណត់ហើយនឹងត្រូវបើកជូនក្រោយពី គ.ជ.ប បានទទួលប្រាក់ពីរតនាគារជាតិ
- យោងតាមមាត្រា២៦នៃអនុក្រឹត្យលេខ ១១ អនក្រ.បក ចុះថ្ងៃទី២២ ខែមករា ឆ្នាំ២០២១ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃអគ្គលេខាធិការដ្ឋាននៃគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ចែងថា «... មន្ត្រីរាជការ ដែលត្រូវបានជ្រើសរើសពីក្រសួង ស្ថាប័ននានា ជាមន្ត្រីជាប់កិច្ចសន្យាបម្រើការងារឱ្យ គ.ជ.ប ត្រូវបានរក្សាបៀវត្ស ប្រាក់បំណាច់ផ្សេងៗ អតីតភាពការងារ សម្រាប់ការឡើងថ្នាក់ និងទទួលសោធននិវត្តន៍នៅអង្គភាពដើមរបស់ខ្លួនដដែល»
- ការសូក និងទទួលសំណូកគឺជាអំពើខុសច្បាប់ ដែលត្រូវផ្តន្ទាទោសតាមច្បាប់។

ថ្ងៃអង្គារ ៥កើត ខែបុស្ស ឆ្នាំខាល ចត្វាស័ក ព.ស.២៥៦៦

រាជធានីភ្នំពេញ ថ្ងៃទី ២៧ ខែ ធ្នូ ឆ្នាំ២០២២

**ជ.គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត**

**ប្រធាន**

ប្រាជ្ញ ចន្ទ